01200781

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 02 / 2016
ម៉ោង (Time/Heure): 13:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E367/6

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** ទម្រង់នៃការផ្តល់សក្ខីកម្មរបស់អ្នកជំនាញ 2-TCE-95

១. នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចកោះហៅលោក អ៊ីសា ឧស្មាន (2-TCE-95) ឱ្យមកផ្តល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញលើការប្រព្រឹត្តចំពោះជនជាតិចាម ដោយផ្អែកលើចំណេះដឹងជំនាញដែលគាត់មាន តាមរយៈការនិពន្ធសៀវភៅចំនួនពីរក្បាល ក្នុងអំឡុងពេលគាត់បំពេញការងារជាអ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា (ឯកសារ E367, កថាខណ្ឌ ១០) ។ លោក អ៊ីសា ឧស្មាន បច្ចុប្បន្នមានតួនាទីជាអ្នកវិភាគទិន្នន័យរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។

២. នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង៖ (១) ជូនដំណឹងដល់ភាគីទាំងអស់ជាមុនថា លោក អ៊ីសា ឧស្មាន អាចមិនត្រូវចោទសួរ ជាពិសេស អំពីព័ត៌មានដែលប្រមូលបាននៅក្នុងអំឡុងពេលស៊ើបសួរក្នុងសំណុំរឿង ០០៤ និង (២) អនុញ្ញាតឱ្យមន្ត្រីច្បាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត មានវត្តមាននៅក្នុងសាលសវនាការ នៅក្នុងអំឡុងពេលដែលលោក អ៊ីសា ឧស្មាន ផ្តល់សក្ខីកម្ម

ហេតុដូចេះហើយ ប្រសិនបើមានចោទសួរសំណួរណាមួយកើតឡើងទាក់ទងនឹងវិសាលភាពត្រឹមត្រូវនៃសក្ខីកម្មរបស់ខ្លួន អ្នកជំនាញអាចពិគ្រោះយោបល់ជាមួយមន្ត្រីច្បាប់រូបនោះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងភាគីទាំងអស់ (ឯកសារ E367/1, ទំព័រ ២)។

៣. ភាគីនានាបានធ្វើសារណាផ្ទាល់មាត់អំពីវិធានការដែលបានស្នើឡើង ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥ ។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនជំទាស់នឹងវិធានការទាំងនោះឡើយ (ប្រតិចារឹក ថ្ងៃទី៣០ ខែ កញ្ញា ឆ្នាំ ២០១៥, ទំព័រ ៦៨ ដល់ ៦៩) ។ មេធាវីការពារក្តីលោក នួន ជា បានលើកឡើងថា វត្តមានរបស់មន្ត្រីច្បាប់នៃការិយាល័យសហចៅក្រមស៊ើបអង្កេត នៅក្នុងសាលសវនាការធ្វើឱ្យមានបញ្ហាចំពោះគោលជំហរ និងពាក់ព័ន្ធដល់បញ្ហាថាតើ បុគ្គលរូបនេះគួរត្រូវបានអនុញ្ញាតឱ្យអន្តរាគមន៍ដែរ ឬ យ៉ាងណា នៅក្នុងកិច្ចដំណើរការនីតិវិធី (ប្រតិចារឹក ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១៥, ទំព័រ ៦៩ ដល់ ៧៤)។ មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា អ្នកជំនាញគួរឆ្លើយសំណួរដោយមិនចាំបាច់ត្រូវការជំនួយ ហើយមន្ត្រីច្បាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត មិនគួរត្រូវបានអនុញ្ញាតឱ្យជួយផ្តល់ចម្លើយទៅអ្នកជំនាញឡើយ (ប្រតិចារឹកថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥ ទំព័រ ៧៣ ដល់ ៧៤)។

៤. តាមរយៈសារអេឡិចត្រូនិកនៅថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១៦ ជាការឆ្លើយតបទៅនឹងការចោទសួរពីអង្គជំនុំជម្រះសាលាដំបូង មន្ត្រីច្បាប់ការិយាល័យសហចៅក្រមស៊ើបអង្កេត បានជម្រាបដល់អង្គជំនុំជម្រះថា ចៅក្រម Bohlander "យល់ឃើញថា ការចោទប្រកាន់ជនសង្ស័យនៅក្នុងសំណុំរឿងផ្សេងដែលបានធ្វើឡើងកាលពី ខែ ធ្នូ មិនមានផលប៉ះពាល់ណាមួយដល់តម្រូវការក្នុងការរក្សាការសម្ងាត់នៃកិច្ចស៊ើបអង្កេតឡើយ រួមបញ្ចូលទាំងបច្ចេកទេស និងវិធីសាស្ត្រ។ ហេតុដូច្នេះ លក្ខខណ្ឌទាំងពីរដែលបានដាក់កាលពីពេលកន្លងមក ដែលលោកបានលើកឡើងក្នុងសារអេឡិចត្រូនិកនាថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១៦ នៅតែមានសុពលភាព ។ គាត់យល់ថា តួនាទីរបស់មន្ត្រីច្បាប់គឺជួយផ្តល់យោបល់ដល់លោក អ៊ីសា ឧស្មាន ឱ្យបដិសេធមិនឆ្លើយសំណួរណាដែលអាចពាក់ព័ន្ធនឹងព័ត៌មានដែលបានប្រមូល ឬ បញ្ហាដែលស្ថិតក្រោមការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ ។ មន្ត្រីច្បាប់រូបនេះមិនមានតួនាទីឆ្លើយតបទៅអង្គជំនុំជម្រះ ឬ ភាគីឡើយ។ សំណួរផ្សេងៗដែលបានកើតឡើងចំពោះករណីដែលលោក អ៊ីសា ឧស្មាន បដិសេធមិនឆ្លើយតប ម្ចាស់សំណួរត្រូវសួរដោយផ្ទាល់ទៅគាត់ មិនមែនសួរទៅមន្ត្រី

ផ្តល់យោបល់ដែលជាអ្នកតំណាងឱ្យចៅក្រម ដែលបំពេញការងារតាមការណែនាំរបស់ចៅក្រមនោះឡើយ”។

៥. អនុលោមតាមវិធាន ៥៦(១) លោក អ៊ីសា ឧស្មាន មានភារកិច្ច “រក្សាឱ្យបាននូវការសម្ងាត់” ពាក់ព័ន្ធការងាររបស់ខ្លួនក្នុងកិច្ចស៊ើបអង្កេតសំណុំរឿង 00៤ ។ ដោយសារតែមិនមានបទប្បញ្ញត្តិគតិយុត្តិណាមួយ ដែលចែងអំពីថាតើ អ្នកតំណាងរបស់ការិយាល័យដទៃរបស់ អ.វ.ត.ក.អាចមានវត្តមានដែរឬអត់នៅក្នុងតុលាការ ដើម្បីធានាដល់ការងាររបស់ការិយាល័យនោះ អង្គជំនុំជម្រះសាលាដំបូង ដោយកត់សម្គាល់ថា ការិយាល័យសហចៅក្រមស៊ើបអង្កេតគឺជាស្ថាប័នជាក់លាក់មួយចំពោះក្របខណ្ឌគតិយុត្តិនៃ អ.វ.ត.ក. បានពិនិត្យមើលទៅលើសេណារីយ៉ូជិតស្និទ្ធបំផុត នៅក្នុងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ ដើម្បីជាការណែនាំ។ ដោយផ្អែកទៅការពិនិត្យលើយុត្តិសាស្ត្របែបនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ចំណុចនេះគឺស្ថិតក្រោមឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ[1] ហើយសម្រេចផ្តល់ការអនុញ្ញាតឱ្យមន្ត្រីច្បាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត មានវត្តមាននៅក្នុងសាលសវនាការក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់លោក អ៊ីសា ឧស្មាន ។ មន្ត្រីច្បាប់របស់ការិយាល័យសហ

---

[1] រដ្ឋអាជ្ញា តទល់នឹង *Slobodan Milošević*, អង្គជំនុំជម្រះសាលាដំបូង TCTY, IT-02-54-*AR108bis* & AR73.3, ឯកសារសាធារណៈនៃសេចក្តីសម្រេចសម្ងាត់ស្តីពីការបកស្រាយ និងអនុវត្តនៃវិធាន៧០, ថ្ងៃទី២៣ ខែតុលា ឆ្នាំ២00២, កថាខណ្ឌ ៣៣។ ក្រោយមកមាននៅក្នុងសេចក្តីសម្រេចសម្ងាត់របស់រដ្ឋអាជ្ញា តទល់នឹង *Slobodan Milošević*, សេចក្តីសម្រេចលើសំណើរបស់ រដ្ឋអាជ្ញាសុំសាក្សី អនុលោមតាមវិធាន ៧0(ខ), ថ្ងៃទី៣0 ខែតុលា ឆ្នាំ២00៣ (“អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិ ក្នុងការអនុញ្ញាតឱ្យមានវត្តមានរបស់តំណាងនៃអ្នកផ្តល់ព័ត៌មាននៅក្នុងតុលាការ ក្នុងពេលផ្តល់ភស្តុតាង”)។ សូមមើលផងដែរ រដ្ឋអាជ្ញាតទល់នឹង *Dragomir Milošević,* អង្គជំនុំជម្រះសាលាដំបូង TCTY, IT-98-29/1-T, សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញា ស្នើសុំការផ្តល់សក្ខីកម្មរបស់សាក្សី W-46 អនុលោមតាមលក្ខខណ្ឌក្នុងវិធាន ៧0, ថ្ងៃទី១២ ខែមីនា ឆ្នាំ២00៧, ទំព័រ ៤ (“តំណាង រដ្ឋាភិបាលរបស់សាក្សី W-46 ត្រូវបានអនុញ្ញាតឱ្យមានវត្តមាន នៅក្នុងពេលផ្តល់សក្ខីកម្មរបស់សាក្សី ប៉ុន្តែមិនត្រូវអន្តរាគមន៍ឡើយ លុះត្រាតែមានការលេចឡើងនូវបញ្ហាសន្តិសុខជាតិ”)។ រដ្ឋអាជ្ញា តទល់នឹង *Milutinović et al* អង្គជំនុំជម្រះសាលាដំបូង TCTY, IT-05-87-T, សេចក្តីសម្រេចលើញត្តិសាជាថ្មីលើកទីពីររបស់រដ្ឋអាជ្ញា ស្នើសុំការអនុញ្ញាតឱ្យធ្វើវិសោធនកម្មលើបញ្ជី អនុលោមតាមវិធាន ៦៥ ស្ទួនពីរ ដើម្បីបន្ថែម Michael Phillips និង Shaun Byrnes (ថ្ងៃទី១២ ខែមីនា ឆ្នាំ២00៧), កថាខណ្ឌ ៣៥។ រដ្ឋអាជ្ញា តទល់នឹង *Mladic,* អង្គជំនុំជម្រះសាលាដំបូង TCTY, IT-09-92-T, សេចក្តីសម្រេចលើញត្តិបន្ទាន់ សុំវិធានការ និងលក្ខខណ្ឌការពារសម្រាប់សាក្សី RM-401 អនុលោមតាមវិធាន ៧0, ថ្ងៃទី១៨ ខែតុលា ឆ្នាំ២0១៣, កថាខណ្ឌ ១0 (“វត្តមានរបស់តំណាងនៃអ្នកផ្តល់ព័ត៌មាន អនុលោមតាមវិធាន៧0 នៅក្នុងតុលាការ អាចនាំទៅដល់ការដោះស្រាយភ្លាមៗ លើបញ្ហានានាពាក់ព័ន្ធថាតើ សំណួរជាក់លាក់ណាខ្លះដែលសាក្សីអាចឆ្លើយតបបានក្នុងសវនាការសាធារណៈ")។

ចៅក្រមស៊ើបអង្កេតនឹងមានវត្តមាន ដើម្បីតំណាងឱ្យផលប្រយោជន៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងការរក្សាការសម្ងាត់ដល់ការស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត មិនមែនជាអ្នកតំណាងផ្លូវច្បាប់របស់អ្នកជំនាញឡើយ។ ដោយពិចារណាអំពីសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ការព្រួយបារម្ភរបស់ក្រុមមេធាវីការពារក្ដី និងលក្ខខណ្ឌរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនោះ អង្គជំនុំជម្រះសាលាដំបូងបង្គាប់ថា មន្ត្រីច្បាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនត្រូវអន្តរាគមន៍ឡើយ លើកលែងតែមានបញ្ហាពាក់ព័ន្ធនឹងការសម្ងាត់នៃការស៊ើបអង្កេតលើសំណុំរឿង ០០៤ ។

៦. អង្គជំនុំជម្រះកត់សម្គាល់ថា វិសាលភាពនៃសក្ខីកម្មរបស់អ្នកជំនាញរូបនេះ ត្រូវបានសម្រេចរួចហើយតាមរយៈសេចក្ដីសម្រេច E367 របស់អង្គជំនុំជម្រះសាលាដំបូង។ យោងតាមសេចក្ដីសម្រេចនេះ លោក អ៊ីសា ឧស្មាន "អាចត្រូវបានសួរដេញដោលទៅលើបញ្ហាទាំងអស់ដែលជាចំណេះដឹង ឬ ជំនាញរបស់គាត់ ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះជនជាតិចាម ក្នុងសំណុំរឿង ០០២/០២" ជាពិសេស ចំណេះដឹងពិសេសដែលគាត់ទទួលបានតាមរយៈការងារ និងការស្រាវជ្រាវរបស់គាត់ ក្នុងការនិពន្ធសៀវភៅចំនួនពីរ (ឯកសារE367,កថាខណ្ឌ ១០ និងផ្នែកសម្រេចសេចក្ដី)។ អង្គជំនុំជម្រះសាលាដំបូងទទួលខុសត្រូវសំខាន់ក្នុងការសម្រេចទៅលើភាពពាក់ព័ន្ធនៃការសួរដេញដោល និងភស្តុតាង។

៧. ប្រសិនបើក្នុងអំឡុងនៃកិច្ចដំណើរការនីតិវិធី អ្នកជំនាញលើកឡើងពីការព្រួយបារម្ភអំពី ថាតើការឆ្លើយសំណួរជាសាធារណៈ អាចឈានទៅដល់ការបំពានលើការសម្ងាត់នៃកិច្ចស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ឬ យ៉ាងណានោះ អង្គជំនុំជម្រះនឹងសម្រេចថាតើជាការសមស្របដែរ ឬ យ៉ាងណា ក្នុងការចាត់វិធានការផ្សេងៗ រួមទាំងការរៀបចំសវនាការអសាធារណៈផងដែរ។